ASIAN AMERICANS ADVANCING JUSTICE
ASIAN LAW CAUCUS

# *Chhoeun v. Marin* Community Advisory: April 2020 Court Order Requiring Notice

## *Chhoeun v. Marin* ក្រុមប្រឹក្សាពិគ្រោះយោបល់សហគមន៍ សេចក្តីជូនដំណឹងពីតម្រូវការដីកាតុលាការ ខែមេសាឆ្នាំ២០២០

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ តុលាការសហព័ន្ធមួយបានចេញសេចក្តីបង្គាប់បញ្ជាជាអចិន្ត្រៃយ៍ (ប្រភេទដីកាតុលាការ) ប្រឆាំងនឹង ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ក្នុងលក្ខណៈពាក្យបណ្តឹងជាក្រុម មានឈ្មោះថា ***Chhoeun v. Marin***។ សេចក្តីបង្គាប់បញ្ជាតម្រូវអោយ ICE ត្រូវតែផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមុននឹងធ្វើការចាប់ឃុំខ្លួនប្រជាជនកម្ពុជាមួយចំនួនឡើងវិញ ដែលមានជាប់ជាមួយការចោទប្រកាន់នឹងដីការនិរទេស។ តុលាការបានសំរេចអនុម័តអោយការិយាល័យមេធាវីមកពីអង្គការមិនស្វែងរកប្រាក់ចំនេញឈ្មោះ Asian Law Caucus និងការិយាល័យមេធាវី Sidley Austin ដើម្បីជាតំណាងអោយក្រុមពាក្យបណ្តឹងនេះ។

### <u>**តើខ្ញុំត្រូវបានការពារដោយសេចក្តីបង្គាប់បញ្ជានេះដែរឬទេ?**</u>

សេចក្តីបង្គាប់បញ្ជានេះផ្តល់ការការពារដល់សមាជិកក្នុងក្រុមពាក្យបណ្តឹង ***Chhoeun v. Marin*** ។ សមាជិករាប់បញ្ចូលរួមមានទាំងប្រជាជនកម្ពុជាដែលនៅក្នុងសហរដ្ឋអាមេរិកទាំងអស់ដែលមានលក្ខណៈសំនុំរឿងដូចខាងក្រោម៖

១. បានទទួលការចោទប្រកាន់និរទេសចុងក្រោយ ឬការបណ្តេញចេញ

២. បានទទួលបានការដោះលែងពីមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ប៉ុន្តែត្រូវស្ថិតក្នុងការគ្រប់គ្រងរបស់គេ

៣. ហើយចាប់តាំងពីពេលនោះមក មិនមានការប្រព្រឹត្តបទល្មើសខុសច្បាស់ណាមួយ ឬក៏បានបំពានលើបទបញ្ជាការគ្រប់គ្រងរបស់គេតាមរបៀបបែបផែនផ្សេងៗទៀតទេ។

ក្រុមមេធាវីការពារពាក្យបណ្តឹងនេះមិនមានបញ្ជីឈ្មោះមនុស្សគ្រប់រូបដែល ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ជឿជាក់ថារាប់ចូលជាសមាជិកក្នុងពាក្យបណ្តឹងនេះ ប៉ុន្តែបើសំនុំរឿងរបស់អ្នកមានលក្ខណៈដូចបានរៀបរាប់ខាងលើ អ្នកគួរតែទទួលបានការកាពារពីការចោទប្រកាន់នេះ។

### <u>**តើសេចក្តីបង្គាប់បញ្ជាមានសុពលភាពយូរប៉ុណ្ណាដែរ?**</u>

សេចក្តីបង្គាប់បញ្ជានេះមិនអស់សុពលភាពនោះទេ។ ទោះជាយ៉ាងណាយើងជឿថារដ្ឋាភិបាលនឹងប្តឹងឧទ្ធរណ៍លើការសំរេចចិត្តរបស់តុលាការ។ បណ្តឹងឧទ្ធរណ៍ប្រហែលត្រូវការរយៈពេលពីរឆ្នាំ ឬយូរជាងនេះ។ ដូច្នេះហើយសេចក្តីបង្គាប់បញ្ជានេះរំពឹងនឹងមានរយៈពេលយ៉ាងហោចណាស់ដល់ឆ្នាំ២០២២។

## តើសេចក្តីបង្គាប់បញ្ជានេះអាចជួយអ្វីខ្លះ?

១. ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ត្រូវតែផ្ញើរសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ១៤ថ្ងៃជាមុន មុនពេលដែលពួកគេមានគំរោងចាប់ខ្លួនសមាជិកក្រុមពាក្យបណ្តឹង។ សមាជិកប្រហែលជាមិនបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ១៤ថ្ងៃពេញនោះទេ។

២. ជាផ្នែកមួយនៃសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍ )ត្រូវតែផ្តល់ដល់សមាជិកនូវច្បាប់ចំលងឯកសារចោទប្រកាន់នានាពីតុលាការអន្តោប្រវេសន៍ក៏ដូចជាដីការបង្គាប់បណ្តេញចេញព្រមជាមួយនឹងកំណត់ត្រាប្រវត្តិផ្តន្ទាទោសឧក្រិដ្ឋកម្មព្រហ្មទ័ណ្ឌរបស់សមាជិកម្នាក់នោះ។ ទាំងនេះអាចជួយអោយសមាជិកអាចមានឱកាសពិគ្រោះយោបល់ជាមួយមេធាវីអន្តោប្រវេសន៍ ថាតើពួកគេអាចបើករឿងក្តីរបស់ពួកគេឡើងវិញ និងដើម្បីលុបចោល ឬបដិសេធនូវដីការបណ្តេញចេញនោះ ។

៣.ច្បាប់ចំលងនៃសេចក្តីជូនដំណឹងនិងឯកសារត្រូវតែប្រគល់ជូនដល់ក្រុមមេធាវីដែលតំណាងអោយក្រុមផងដែរ។

## តើសេចក្តីបង្គាប់បញ្ជានេះមិនអាចជួយអ្វីខ្លះ?

១. សេចក្តីបង្គាប់បញ្ជានេះមិនមានប្រសិទ្ធិភាពអាចការពាររារាំងទប់ស្កាត់មិនអោយ ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ពីការចាប់ខ្លួនសមាជិកនោះឡើយ។ ICE អាចនៅតែអាចចាប់ខ្លួនសមាជិកបានដរាបណាពួកគេផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ១៤ថ្ងៃជាមុន។

២. សេចក្តីបង្គាប់បញ្ជានេះមិនតំរូវអោយ ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) បញ្ជាក់ថាពេលណា ទីកន្លែងណា ឬក៏គំរោងពួកគេនឹងចាប់ខ្លួនសមាជិកមានលក្ខណៈរបៀបណានោះទេ។ សំរាប់ជនមួយចំនួនជូនដំណឹងអោយទៅរាយការណ៍នៅការិយាល័យប្រចាំតំបន់ដោយមានបញ្ជាក់កាលបរិច្ឆេទជាក់លាក់ដែលត្រូវចាប់ខ្លួន។ សំរាប់ជនមួយចំនួនទៀតជូនដំណឹងថានឹងមានការចាប់ខ្លួនពួកគេមិនតិចជាង១៤ថ្ងៃចាប់គិតពីថ្ងៃនេះទៅ ដោយមិនមានប្រាប់ពីពេលវេលា ឬទីកន្លែងលំអិតណាមួយនោះទេ។

៣. សេចក្តីបង្គាប់បញ្ជានេះមិនមានប្រសិទ្ធិភាពអាចការពាររារាំងទប់ស្កាត់មិនអោយ ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ពីការធ្វើនិរទេសសមាជិកក្រុមនោះទេ។

## តើខ្ញុំអាចពិភាក្សាជាមួយមេធាវីបានឬទេ?

ប្រសិនបើអ្នកមានសំនួរមួយចំនួនស្តីអំពីរដីការនេះឬក៏យល់ថា ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍)បានចាប់ខ្លួនសមាជិកក្រុមដោយមិនបានផ្តល់ការជូនដំណឹង និងឯកសារចាំបាច់ជាមុនដល់ពួកគេសូមទូរស័ព្ទទៅលេខ **415-952-0413** ដើម្បីពិភាក្សាជាមួយមេធាវីប្រចាំការិយាល័យ Asian Law Caucus ដោយឥតគិតថ្លៃ។

លោកអ្នកអាចទូរស័ព្ទទៅលេខ **415-952-0413** ដើម្បីពិភាក្សាជាមួយមេធាវីប្រចាំការិយាល័យ Asian Law Caucus ដោយឥតគិតថ្លៃពីការត្រូវទៅជួបជាមួយ ICE (ទីភ្នាក់ងារដាក់កំហិតច្បាប់អន្តោប្រវេសន៍) ឬពីការមានជំរើសលើបើកក្តីសំនុំរឿងបណ្តេញចេញរបស់អ្នកឡើងវិញ។ យើងមិនចាំបាច់តំណាងអោយអ្នកក្នុងករណីក្តីអន្តោប្រវេសន៍បៀបឯកជននោះទេ ប៉ុន្តែយើងអាចផ្តល់ការពិគ្រោះយោបល់ដល់អ្នកបាន។

# *Chhoeun v. Marin* Community Advisory: April 2020 Court Order Requiring Notice

On April 27, 2020, a federal judge issued a permanent injunction (a type of court order) against ICE in a class action lawsuit, *Chhoeun v. Marin*. The injunction requires ICE to provide written notice before re-detaining certain Cambodians with deportation orders. The court has approved lawyers from the nonprofit organization Asian Law Caucus and the law firm Sidley Austin to represent the "class" in the lawsuit.

## Am I protected by the injunction?

The injunction protects the class in *Chhoeun v. Marin*. The class includes all Cambodians in the United States who:

1. Received a final order of deportation or removal
2. Were then released from immigration detention on an order of supervision
3. And since then, have not been convicted of a crime or violated their order of supervision in some other way.

The lawyers for the class do not have a list of every person who ICE believes is in the class, but if you meet the description above, you should be protected by the injunction.

## How long will the injunction last?

The injunction does not expire. However, we believe the government will appeal the judge's decision. An appeal will probably take two years or longer, so the injunction is expected to last at least until sometime in 2022.

## What does the injunction do?

1. ICE must mail a written notice at least 14 days in advance that they plan to arrest a class member. The class member might not receive the written notice a full 14 days in advance.
2. As part of the written notice, ICE must provide the class member with copies of their immigration court charging documents, removal order, and criminal conviction records.

This gives class members a chance to consult with an immigration lawyer about whether they might be able to reopen their case and cancel their removal order.

3. A copy of the notice and documents must also be provided to lawyers who represent the class.

## What does the injunction NOT do?

1. The injunction does not prevent ICE from arresting class members. ICE can still arrest class members as long as they provide written notice at least 14 days in advance.
2. The injunction does not require ICE to say exactly when, where, or how they plan to arrest a class member. For some people, the notice might tell them to report to a specific ICE field office on a specific date to be arrested. For other people, the notice might only say that ICE plans to arrest them no sooner than 14 days from now, without any details about the date or place.
3. The injunction does not prevent ICE from deporting class members.

## Can I talk to a lawyer?

If you have questions about the injunction or believe that ICE has violated the injunction by arresting a class member without giving them the required notice or documents, call (415) 952-0413 to speak to a lawyer at the Asian Law Caucus for free.

You can also call (415) 952-0413 to speak to a lawyer at the Asian Law Caucus for free about an upcoming ICE check-in or options for reopening your removal order. We cannot necessarily represent you in your individual immigration case but can provide a consultation.